ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០៧០/១៧ គ.ជ.ប.ជ.

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមីនា និងទិសដៅខែមេសា ឆ្នាំ២០១៧

( គិតចាប់ពីថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែមីនាឆ្នាំ២០១៧ )

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបាន និងកំពុងខិតខំយកចិត្តទុកដាក់ សម្របសម្រួលជំរុញពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន គណៈកម្មាធិការរាជធានី/ខេត្តដៃគូជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធ ធ្វើការងារយ៉ាងសកម្មលើការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ជាក់ស្តែងក្នុងខែមីនា ឆ្នាំ២០១៧ នេះអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលរបាយការណ៍ពីគ្រប់មជ្ឈដ្ឋានក្រោមការដឹងនាំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានមាន៖

- ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់) បានផ្តល់របាយការណ៍ ។ ឯក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ចំនួន៥ ផ្សេងទៀតមិនទាន់បានផ្ញើរបាយការណ៍។
- លេខាធិការដ្ឋានរាជធានី/ខេត្តចំនួន២២ មានរាជធានីភ្នំពេញ ,កោះកុង ,ព្រះសីហនុ ,កំពត ,តាកែវ ,កណ្តាល ព្រៃវែង,ឧត្តរមានជ័យ ,ប៉ៃលិន,បន្ទាយមានជ័យ,បាត់ដំបង ,ពោធិ៍សាត់ ,ព្រះវិហារ,សៀមរាប,កំពង់ធំ ,ក្រចេះ ស្ទឹងត្រែង ,រតនគិរី , កំពង់ចាម ,កំពង់ឆ្នាំង ,កំពង់ស្ពឺ និងខេត្តស្វាយរៀង បានផ្តល់របាយការណ៍។ ឯលេខាធិការដ្ឋានរាជធានី/ខេត្តចំនួន ៣ គឺខេត្តកែប ត្បូងឃ្មុំ និងខេត្តមណ្ឌលគិរី នៅមិនទាន់បានផ្ញើរបាយការណ៍។

## II. ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ

### ក.ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ដើម្បីសម្រេចបានតាមផែនការ យុទ្ធសាស្ត្រសកម្មភាពជាតិ អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួង ស្ថាប័ន ជំនាញ ដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ ក្នុងនោះមានស្ថានទូតផងដែរ សម្រេចបានលិខិតបទដ្ឋានគតិយុត្តិមួយចំនួនដូចខាងក្រោម៖

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានត្រៀមពិភាក្សាលើផែនការអនុវត្តកិច្ចព្រមព្រៀងកម្ពុជា-ឥណ្ឌា ស្តីពី«កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ។

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចេញសេចក្តីសម្រេចលេខ០៣៧/១៧ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងលោក **ពេញ វិបុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមក្រុមការងារកិច្ចការយុត្តិធម៌ ។
- **ក្រសួងកិច្ចការនារី** បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងការពពោះជំនួស"
- **ក្រសួងយុត្តិធម៌** បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ"
- **ក្រសួងអប់រំ យុវជន និងកីឡា** បាន និងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"

## ខ.លើកកម្ពស់ការបង្ការទប់ស្កាត់

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ តាមប្រធានបទ "ភូមិឃុំមានសុវត្ថិភាព" បានចំនួន៣.១៩២លើក កើនឡើងចំនួន៧១១លើក ស្មើនឹង២៨,៦៥% (ធៀបនឹងខែមុនបានចំនួន២.៤៨១លើក) មានអ្នកចូលរួមសរុបចំនួន៥១៩.៨១៣នាក់ កើនឡើងចំនួន១៩៩.៦៦៤នាក់ ស្មើនឹង៦២,៣៦% (ធៀបនឹងខែមុនមានតែចំនួន៣២០.១៤៩នាក់) ក្នុងនោះស្ត្រីមានចំនួន១៦៨.០៦២នាក់ ។ (ឧបសម្ព័ន្ធទី១)

### ខ.១-ការផលិត និងចែកផ្សាយសម្ភារៈផ្សព្វផ្សាយ

មន្ទីរសង្គមកិច្ចស្រុកសហការជាមួយអធិការដ្ឋាននគរបាលស្រុក និងនាយប៉ុស្តិ៍នគរបាល បានធ្វើការចែកប័ណ្ណដែលមានលេខទូរស័ព្ទរបស់សមត្ថកិច្ច ជូនដល់ប្រជាពលរដ្ឋ ដើម្បីងាយស្រួលពួកគាត់ធ្វើការទំនាក់ទំនងមកសមត្ថកិច្ច ជួយសង្គ្រោះទាន់ពេល ពេលដែលពួកគាត់ជួបរាល់បញ្ហាអសកម្មទាំងឡាយ ឬអំពើរំលោភបំពានផ្លូវភេទ និងអំពើជួញដូរមនុស្សជាដើម ដើម្បីសុវត្ថិភាពក្នុងភូមិ ឃុំរបស់ពួកគាត់ ។

### ខ.២-ផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន

- ខេត្តកំពត បានបញ្ចាំងខ្សែភាពយន្តរឿង "ជើងមេឃនៅឯណា"ចំនួន០២លើក មានអ្នកចូលរួមចំនួន៥៦នាក់(ស្រី២៣នាក់)។
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានធ្វើការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធការជួញដូរមនុស្ស និងបទល្មើសផ្សេងៗ តាមប៉ុស្តិ៍វិទ្យុ បានចំនួន០៤លើក។

## គ.ការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍

### គ.១-ការគ្រប់គ្រងបច្ចុប្បន្នភាពស្ថិតិចំណាកស្រុក

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានចុះធ្វើស្ថិតិពលករចំណាកស្រុក ទៅក្រៅប្រទេស៖

សរុបមានចំនួន៣២១.១៥៩នាក់ (ស្រី១៤០.៥០៧នាក់) អនីតិជន ៧.៨៩៤នាក់ (ស្រី៣.០១៤នាក់) ក្នុងនោះចំណាកស្រុកស្របច្បាប់មានចំនួន១៨០.៧១២នាក់ (ស្រី៨៣.៨១៦នាក់) អនីតិជនចំនួន៥៨៩នាក់ (ស្រី២៤៤នាក់) និងចំណាកស្រុកមិនស្របច្បាប់មានចំនួន១៤០.៤៤៧នាក់ (ស្រី៥៦.៦៩១នាក់) អនីតិជនមានចំនួន៧.៣០៥នាក់(ស្រី២.៧៧០នាក់)។ ស្ថិតិនេះប្រៀបធៀបនឹងខែមុន(កុម្ភៈ)ថយចុះចំនួន១.៩១២នាក់ ស្មើនឹង០,៥៩៨% ។ Sitha

### គ.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន បញ្ជូនពលករទៅធ្វើការនៅបរទេស

ក្រុមហ៊ុនឯកជន បានធ្វើការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ មានចំនួន០១ប្រទេស(ថៃ) ពលករ ចំនួន ៧៧នាក់(ស្រីចំនួន៣៤នាក់) ក្នុងនោះ៖

- តាមរយៈភ្នាក់ងារជ្រើសរើសឯកជនចំនួន០៥លើក នៅក្នុងខេត្តប៉ៃលិន ដែលបានជ្រើសរើសពលករខ្មែរទៅធ្វើការនៅប្រទេសថៃ មានក្រុមហ៊ុនចំនួន០៤ ៖

- ក្រុមហ៊ុន UNICORN MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន ១៥នាក់(ស្រី០៤នាក់) ។
- ក្រុមហ៊ុន B.S.R.O BETS MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន២០នាក់(ស្រី១០នាក់) ។
- ក្រុមហ៊ុន SUPA WICH PATANAKIT CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន១៤នាក់(ស្រី០២នាក់)លើកទី១ និងចំនួន១៤នាក់(ស្រី០៩នាក់)លើកទី២ ។
- ក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន១៤នាក់(ស្រី០៩នាក់) ។

### គ.៣-ស្ថានភាពលំហូរជនទេសន្តរប្រវេសន៍

តាមរបាយការណ៍ពីគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបន្ទាយមានជ័យ ក្រុមការងារទទួលជនទេសន្តរប្រវេសន៍បានឲ្យដឹងថា ថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន ១៣៨ជើងរថយន្ត មានពលករខ្មែរសរុបចំនួន៦,១៣២នាក់ ស្រីចំនួន២,២២៩នាក់ ក្នុងនោះកុមារចំនួន៦០៤នាក់ (កុមារី២៥២នាក់)។ បើប្រៀបធៀបនឹងខែកុម្ភៈ មានការកើនឡើងចំនួន៣៨៣នាក់។ តាមរយៈការសម្ភាសខ្លី បានរកឃើញថា៖

- បានចេញតាមច្រកអន្តរជាតិ **២,៤៤៧** នាក់ តាមច្រករបៀង **៣,៦៨៥** នាក់
- ចេញដោយខ្លួនឯង **២,៧៦៧** នាក់ តាមរយៈគេនាំ **៣,៣៦៥** នាក់
- <u>**បានជាប់ពន្ធនាគារ លើសពី ១ខែ មាន ៣០៥ នាក់**</u> ។

តាមការសម្ភាសបានឲ្យដឹងថា ពួកគាត់មានខ្លះជាប់ឃុំរយៈពេល១៥ឆ្នាំ, ១២ឆ្នាំ, ០៨ឆ្នាំ ដោយមូលហេតុខ្លះស៊ីឈ្នួលកាន់គ្រឿងញៀន ខ្លះចូលទៅលួចកាប់ឈើគ្រញូង ខ្លះស៊ីឈ្នួលដឹករបស់ក្លែងក្លាយ ខ្លះកាន់ប៉ាស្ព័ររូបអ្នកផ្សេងដែលមេខ្យល់ឲ្យកាន់ ចំណែកអ្នកជាប់រយៈពេល២ខែច្រើនជាអ្នកគ្មានប័ណ្ណស្នាក់នៅ ។

ក្រុមការងារបានសម្ភាសពលករចំនួន**២៨៤**នាក់ (ស្រី**១១៥**នាក់) មិនបានរកឃើញអត្តសញ្ញាណជនសង្ស័យនាំមនុស្សឆ្លងដែនទេ។

ក្នុងនោះបានសម្ភាសកុមារចំនួន**៥០**នាក់ (កុមារី **២៣**នាក់) ពិនិត្យឃើញថា៖

- កុមារ**២៩**នាក់ ទៅតាមឳពុកម្ដាយ និងកុមារ**២១**នាក់ ទៅតាមបងប្អូន ។

### គ.៤-វិធានការគ្រប់គ្រងជំនាញ

#### គ.៤.១-ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ

- ស្នងការដ្ឋាននគរបាល**ខេត្តសៀមរាប និងខេត្តស្វាយរៀង** បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារ ក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**៦០៧**គោលដៅ មានមនុស្សធ្វើការចំនួន**៣.៦៤១**នាក់ (ស្រី**២.៩៥៤**នាក់)។

- តាមដាន និងឃ្លាំមើលបានចំនួន៦០៧គោលដៅ កើនឡើង ៤៧០គោលដៅ បើប្រៀបធៀបខែមុនមានចំនួនតែ ១៣៧គោលដៅ ស្មើនឹង ៣៤៣,០៦% មានមនុស្សធ្វើការចំនួន៣.៦៤១នាក់ កើនឡើងចំនួន ២.០៨៦នាក់ ស្មើនឹង១៣៤.១៤% (ស្ត្រី២.៩៥៤នាក់) បើប្រៀបធៀប ខែមុនមានចំនួនតែ១.៥៥៥នាក់ ។
- ស្នងការដ្ឋាននគរបាល**ខេត្តបន្ទាយមានជ័យ** បានធ្វើការបង្ក្រាបទប់ស្កាត់ប្រជាពលរដ្ឋខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០១លើក មនុស្សចំនួន២២នាក់(ស្រី១៣នាក់)។
- **បច្ចុប្បន្នភាព ទិន្នន័យគោលដៅសង្ស័យ** ការប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទនៅរាជធានី-ខេត្ត មានចំនួន៦០គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សមានចំនួន២៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៣១គោលដៅ ។

**គ.៤.២-ការបង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស**

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការ បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍បានចំនួន១៤០គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួន (រស់នៅជាមួយគ្រួសារមានសេចក្ដីសុខសប្បាយជាធម្មតា)។

## ឃ.ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

**ឃ.១ ការងារអនុវត្តច្បាប់**

**ឃ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ) បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន១២ករណី/១៦ករណី(បើប្រៀបធៀប ខែមុនថយចុះ០៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន១៤នាក់(ស្រី០៤នាក់ ក្នុងនោះជាអនីតិជន០៣នាក់) សង្គ្រោះជនរងគ្រោះបានចំនួន២០នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០៨នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០២នាក់ និងអាយុ១៨ឆ្នាំឡើងបានចំនួន១០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ចំនួន១២នាក់ និង០៨នាក់ទៀតប្រគល់ឲ្យគ្រួសារ) ។

- **ការបង្ក្រាបអំពើជួញដូរមនុស្ស**

សរុបបាន០១ករណី/០៥ករណី ជនសង្ស័យចំនួន០១នាក់។

- នាំឆ្លងដែន ០១ករណី ជនសង្ស័យ ០១នាក់

- **ការបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ**

សរុប១១ករណី/១១ករណី ជនសង្ស័យចំនួន១៣នាក់(ស្រី០៤នាក់)ក្នុងនោះជាអនីតិជន០៣នាក់ ជនរងគ្រោះចំនួន២០នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០៨នាក់ អាយុពី១៥-១៧ឆ្នាំ០២នាក់ អាយុ១៨ឆ្នាំឡើងចំនួន១០នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១២នាក់ និង០៨នាក់ ទៀតប្រគល់ឲ្យគ្រួសារ) ។

| | |
|---|---|
| -សញ្ជារកម្ម | ០១ករណី ជនសង្ស័យ ០២នាក់ |
| -ស្ថានភាពទម្ងន់ទោសនៃសញ្ជាកម្ម | ០១ករណី ជនសង្ស័យ ០២នាក់ |
| -សញ្ជារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ ) | ០១ករណី ជនសង្ស័យ ០១នាក់ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ករណី ជនសង្ស័យ ០៦នាក់ (ជាអនីតិជន០១នាក់) |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ករណី ជនសង្ស័យ ០២នាក់ (ជាអនីតិជន០២នាក់) |

ឃ.២ កិច្ចការយុត្តិធម៌

ឃ.២.១ លទ្ធផលចំណាត់ការផ្តន្ទាទោស(ពុំមានទិន្នន័យ)

ឃ.២.២-ការរៀបចំបទដ្ឋានគតិយុត្តិ និងច្បាប់

- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" កំពុងពិភាក្សាមានៈ
  - សន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី ។
- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បត្យាប័ន" កំពុងពិភាក្សាមានៈ
  - សន្ធិសញ្ញា ស្តីពី "បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលឥណ្ឌា ។
- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បញ្ជូនទណ្ឌិត" កំពុងពិភាក្សាមានៈ
  - សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស និង រដ្ឋាភិបាលប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ និង រដ្ឋាភិបាលរុស្ស៊ី ។

## ង.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

### ង.១- ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន

របាយការណ៍ទទួលពីក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការនគរបាលជាតិ) ពលករទេសន្តប្រវេសន៍ ការងារបញ្ជូនត្រឡប់មកពីច្រកព្រំដែនកម្ពុជា-ថៃ និងច្រកព្រំដែនកម្ពុជា-វៀតណាម សរុបចំនួន **១៩.៧១៧**នាក់ (ស្រី**៧.៧៦៨**នាក់)អនីតិជនចំនួន៩០១នាក់ (ស្រី៣២៧នាក់) ដែលមកតាម ៖

- ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ**៧.១២៦**នាក់(ស្រី **២.៦០៣**នាក់,អនីតិជន**៧១៧**នាក់ (ស្រី**២៩៣**នាក់)
- ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង **១២.១៤៤**នាក់ (ស្រី**៥.០០១**នាក់ ,កុមារ**១២៩**នាក់)
- ច្រកភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង**៤០៩**នាក់(ស្រី**១៤១**នាក់ ,កុមារ**៣១**នាក់ ,កុមារី**១៨**នាក់)
- ច្រកអានសេះ ខេត្តព្រះវិហារ០៩នាក់
- ច្រកអន្តរជាតិបាវិត ខេត្តស្វាយរៀង ៣៨នាក់ (ស្រី២៤នាក់ ,អនីតិជន២៤នាក់ ,ស្រី១២នាក់)

ចំណែកក្នុងនោះពលរដ្ឋខ្មែរចំនួន៤៤២នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។ ចំពោះទេសន្តប្រវេសន៍ទាំងអស់នោះ ត្រូវអប់រំណែនាំឲ្យត្រឡប់ទៅលំនៅឋានវិញ ។

### ង.២-ការសម្ភាសពលករចាប់បញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានសម្ភាសដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញារងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រទេសថៃបញ្ជូនមក បាន**ចំនួន១០នាក់**(ស្ត្រី០៤នាក់) ក្នុងនោះបានដកហូតកុមារដែលមិនមានមនុស្សធំអមដំណើរមកជាមួយមានចំនួន**០៧**នាក់ (កុមារី ០៣នាក់,កុមារា០៤នាក់)។ បញ្ជាក់១០នាក់នេះ ជាករណីងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ។
- ក្រុមការងារលេខាធិការដ្ឋានស្រុកចម្ការលើ ខេត្តកំពង់ចាម បានទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្សមកពីប្រទេសម៉ាឡេស៊ីចំនួន០២នាក់ ។
- ក្រុមការងារលេខាធិការ គ.ខ.ប.ជ ខេត្តកំពង់ធំ បានជួយអន្តរាគមន៍ជនរងគ្រោះទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ០១នាក់ និងបានធ្វើការអប់រំណែនាំ រួចបញ្ជូនឲ្យទៅរស់នៅស្រុកកំណើតវិញ ។
- ក្រុមការងារការពារជួយជនរងគ្រោះ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស មានចំនួន**១៦**នាក់ (ស្រី**១២**នាក់) ក្នុងនោះ៖

- មកពីប្រទេសថៃ ចំនួន០៤នាក់ (ស្រី០៣នាក់)
- មកពីប្រទេសម៉ាឡេស៊ី ចំនួន០៧នាក់ (ស្រី០៤នាក់)
- មកពីប្រទេសចិន ចំនួន០៥នាក់ (ស្រី០៥នាក់)

**ង.៣ ការគ្រប់គ្រងជនងាយរងគ្រោះនៅក្នុងមណ្ឌល**

**រាជធានីភ្នំពេញ** បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន១៣២នាក់ (ស្រី៤៦នាក់ ,កុមារចំនួន ២០នាក់ កុមារី០៦នាក់ ដោយបញ្ជូនជនរងគ្រោះទាំងនេះ ទៅមណ្ឌលសំចតមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ដើម្បី អប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។

**ង.៤ សេវាជួយជនរងគ្រោះដែលបានផ្តល់**

**ខេត្តបន្ទាយមានជ័យ** មណ្ឌលសំចតបានបញ្ជូនជនរងគ្រោះទាំង១១នាក់ ទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក្នុងនោះមានស្ត្រី០២នាក់,កុមារី០១នាក់,កុមារា០២នាក់។ អង្គការជំណាក់ទឹកស្ត្រី០២នាក់ កុមារី០១នាក់,កុមារា០២នាក់ និងផ្ទះសហគមន៍របស់អង្គការ A21 កុមារី០១នាក់ ដើម្បីបានទទួលសេវាស្នាក់នៅសុវត្ថិភាពអប់រំក្នុងនិងក្រៅប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងសេវាផ្សេងៗ

**ង.៥ សមាហរណកម្មជនរងគ្រោះ**

**មន្ទីរសង្គមកិច្ចស.អ.យ ខេត្តក្រចេះ** គ្រប់ស្រុក បានចុះពិនិត្យ និងបានសហការជាមួយអង្គការនានា មានដូចជាអង្គការក្តីសង្ឃឹមពិភពលោក ,ទស្សនៈពិភពលោក ,AFESIP ,សង្គ្រោះដោតវាសនា ,មេត្រីអន្តរជាតិដើម្បីអាស៊ី និងអង្គការCCPCR ដែលធ្វើសមាហរណកម្មជនងាយរងគ្រោះចំនួន៤២នាក់ ក្នុងនោះបានរកឃើញជនរងគ្រោះដោយឆ្លងដែនខុសច្បាប់ចំនួន០៦នាក់ ឲ្យមករស់នៅសហគមន៍វិញ ។

## III. ការលើកកម្ពស់សមត្ថភាព

### ក.ក្នុងប្រទេស

ក.១-បណ្តុះបណ្តាល

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការបានសហការជាមួយអង្គការ UNODC បើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា បានចំនួន០១លើក ដែលមានសិក្ខាកាមចំនួន៤៥នាក់ ក្នុងនោះមានជនបរទេស (ម៉ាឡេស៊ី០១នាក់ ,ឥណ្ឌូណេស៊ី០១នាក់ ,ថៃ០១នាក់ ,វៀតណាម និងហ្វីលីពីន០១នាក់ នៅសណ្ឋាគារ Green Palace Hotel រាជធានីភ្នំពេញ ។

- **ខេត្តព្រះសីហនុ** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយមន្ទីរទេសចរណ៍ បើកវគ្គ បណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ច និងសេវាកម្មទេសចរណ៍ ដោយបានបញ្ជ្រាបបញ្ហាយេនឌ័រ ស្តីពីការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ចំនួន០២វគ្គ ដែលមានសិក្ខាកាមចំនួន៧១នាក់ (ស្រី២២នាក់)

- **ខេត្តព្រៃវែង ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តព្រៃវែង បានសហការគ្នាជាមួយអង្គការសម្ព័ន្ធចាប់ដៃគូ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ ដល់សិក្ខាកាមចំនួន២៨នាក់ (ស្រី០៥នាក់) ដែលមកពីស្រុកកំចាយមារ មានឃុំ(ក្របៅ ,ដូងកីង ,ស្មោងជើង និងឃុំក្រញូង) និងស្រុកពារាំង មានឃុំ(ព្រៃញា ,ព្រៃស្រឡិត ,កំពង់ពពិល និងឃុំកំពង់ប្រាំង)

- **ខេត្តស្វាយរៀង** ៖ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិដើម្បីកុមារ បានសហការជាមួយអង្គការអន្តរជាតិកម្ពុជា (ICC) បើកវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិកុមារ និងគោលការណ៍ចូលរួមរបស់កុមារ ដល់ បណ្តាញសហគមន៍ នៅស្រុកកំពង់រោទិ៍ និងស្រុកចន្ទ្រា បានចំនួន៣វគ្គ មានសិក្ខាកាមចំនួន**៨៦**នាក់ (ស្រី**១៦**នាក់)។
- **ខេត្តឧត្តរមានជ័យ** មន្ទីរកិច្ចការនារី បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ធ្វើនៅមន្ទីរកិច្ចការនារីខេត្ត ដល់សិក្ខាកាមចំនួន**៤៥**នាក់ (ស្រី**៣៩**នាក់)។

ក.២-សិក្ខាសាលា

- **ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ** បានរៀបចំសិក្ខាសាលា ស្តីពីក្រុមអ្នកធ្វើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី១ ។
- **ខេត្តព្រៃវែង** គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានរៀបចំសិក្ខាសាលា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួញដូរពលកម្ម នៅសាលប្រជុំសាខាកាកបាទក្រហមកម្ពុជា ខេត្តព្រៃវែង ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងលោក ជា សុមេធី គណៈអភិបាលខេត្ត និងជាគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត មានអ្នកចូលរួមសរុប**១១០**នាក់ ។

ក.៣-សម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួលសរុបបានចំនួន៣៨លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន**១០**លើក ក្រុមការងារអនុវត្តន៍ច្បាប់ចំនួន**០១**លើក និងដោយលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន**២៧**លើក។ (**ឧបសម្ព័ន្ធទី២**)

## ខ.ក្រៅប្រទេស

ខ.១ សកម្មភាពចូលរួមប្រជុំ

- **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងការបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា នៅទីក្រុងហ្វងសាន ខេត្តអានហួយ សាធារណៈរដ្ឋប្រជាមានិតចិន ពីថ្ងៃទី២១-២៣ ខែមីនា ឆ្នាំ២០១៧ ។
- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ នៃគ.ជ.ប.ជ** បានចូលរួមក្នុងវេទិកា Inter pol ស្តីពីការរួមគ្នាដើម្បីសន្តិសុខ និងការទទួលខុសត្រូវ សម្រាប់សន្តិភាពពិភពលោក នៅទីក្រុង Abu Dhabi ប្រទេសអារ៉ាប់រួម ។
- **ខេត្តរតនគិរី** ចូលរួមប្រជុំថ្នាក់ប៉ុស្តិ៍នៃ(វរៈការពារព្រំដែនលេខ៦២៣ និង២០៣)ជាមួយភាគីឡាវ និងភាគីវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងបញ្ហាប្រជាជន ឆ្លងដែនខុសច្បាប់ បានចំនួន០៩លើក ។

ខ.២-សិក្ខាសាលា

**អគ្គស្នងការដ្ឋាននគរបាលជាតិ** ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការបានបញ្ជូននគរបាលជាន់ខ្ពស់ចំនួន០២រូប ចូលរួមសិក្ខាសាលា ស្តីពីកិច្ចសហការអនុវត្តច្បាប់ ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស និងរត់ពន្ធទេសន្តរប្រវេសន៍ ក្នុងតំបន់អាស៊ីអាគ្នេយ៍ (នៅប្រទេសម៉ាឡេស៊ី) ។

## IV. សន្និដ្ឋាន និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើងតាមរយៈ ៖

- របាយការណ៍ប្រចាំខែ ពីបណ្ដាក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន គណៈកម្មាធិការរាជធានី/ខេត្តដៃគូជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធ
- តាមការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្របដល់ជនរងគ្រោះ ក្រោយការបណ្ដុះបណ្ដាលរួមមាន៖ (ខេត្តកណ្ដាល, បន្ទាយមានជ័យ, សៀមរាប, រាជធានីភ្នំពេញ និងខេត្តកំពង់ចាម)
- ការចុះតាមដានការអនុវត្តការងារមន្ត្រីនគរបាលយុត្តិធម៌ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងពេលប្រតិបត្តិការ។

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

១.អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានក្រុមមន្ត្រីជំនួយការប្រកបដោយឆន្ទៈ និងការទទួលខុសត្រូវ។

២.មានសកម្មភាពយុទ្ធសាស្ត្រ ដឹកនាំ សម្របសម្រួល និងកិច្ចសហប្រតិបត្តិការគ្នាល្អ តាមបណ្ដាក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន គណៈកម្មាធិការរាជធានី/ខេត្តដៃគូជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២.យើងមានរបៀបរបបការងារ និងទំនាក់ទំនងយ៉ាងទូលំទូលាយចំពោះអ្នកបម្រើ និងអ្នកទទួលសេវា។

៣.កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៤.បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

### ខ.ចំណុចខ្វះខាត និងបញ្ហាប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ការផ្ដល់របាយការណ៍ ពីក្រុមការងារ និងរាជធានី/ខេត្ត មួយចំនួនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បី ធ្វើការបូកសរុបមានការយឺតយ៉ាវ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតងាយធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។

- របនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។

## V. ទិសដៅខែមេសា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួម បែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ជួញដូរ និងដកហូតសរីរាង្គ ជួញដូរ និងរត់ពន្ធទារក និងកុមារ ឆ្លងដែន ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

៣. រៀបចំសកម្មភាពសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្ដាល អាណត្តិទី២ ៖ ២០១៧-២០១៨) ។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌ ។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។

៨. បន្តរៀបចំសកម្មភាពបណ្ដុះបណ្ដាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាម បណ្ដាក្រសួង ស្ថាប័នអង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត ។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ) ។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ៕

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## ការខារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្ត កោះកុង ,ព្រះសីហនុ ,កំពត ,កំពង់ស្ពឺ ,ស្វាយរៀង ,កំពង់ចាម និងខេត្ត ឧត្តរមានជ័យ បានផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំ មានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 841 លើក | 264,124 នាក់ | 33,783 នាក់ |
| 2 | កោះកុង | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមភូមិឃុំ សង្កាត់ទូទាំងខេត្ត ។ | លេខាធិការដ្ឋានខេត្ត | 27 លើក | 1,388 នាក់ | 653 នាក់ |
| 3 | ប៉ៃលិន | ក្រុមការងារថ្នាក់ សង្កាត់ប៉ៃលិន និងសង្កាត់ទួលល្វា បានចូលរួមផ្សព្វផ្សាយប្រចាំខែរបស់ គ.ក.ន.ក ស្តីពីផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ សង្កាត់ប៉ៃលិន និងសង្កាត់ទួលល្វា | 1 លើក | 34 នាក់ | 28 នាក់ |
| 4 | បាត់ដំបង | បានធ្វើវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយបញ្ជ្រាបការផ្សព្វផ្សាយ ការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 511 លើក | 57,884 នាក់ | 30,051 នាក់ |
| 5 | កណ្តាល | ផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 50 លើក | 2,828 នាក់ | 1,693 នាក់ |
| 6 | ក្រចេះ | មន្ទីរសង្គមកិច្ចខេត្ត បានបើកវគ្គផ្សព្វផ្សាយ ច្បាប់ស្តីពីការទប់ស្កាត់ការអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋនៅឃុំស្រែចារ ស្រុកស្នួល ។ | មន្ទីរសង្គមកិច្ចខេត្ត | 4 លើក | 171 នាក់ | 83 នាក់ |
| 7 | កំពង់ចាម | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជួយឧបត្ថម្ភដោយទីភ្នាក់ងារអូស្ត្រាលីសម្រាប់អភិវឌ្ឍន៍អន្តរជាតិ បានរៀបចំប្រជុំផ្សព្វផ្សាយ គោលនយោបាយទេសន្តរប្រវេសន៍ ស្តីពីក្របខណ្ឌគតិយុត្តនៅកម្ពុជា ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ,មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | 1 លើក | 48 នាក់ | 13 នាក់ |
| | | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ នៅវិទ្យាល័យហ៊ុនសែនសន្ទន់ ក្នុងឃុំសូទិព្វ ស្រុកជើងព្រៃ ។ | | 1 លើក | 302 នាក់ | 134 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | កំពត | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងស្រុក កំពង់ត្រាច ស្រុកទឹកឈូ និងស្រុកបន្ទាយមាស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 116 នាក់ | 66 នាក់ |
| 9 | សៀមរាប | ផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពទាំង១២ក្រុង ស្រុក ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត និងក្រុមការងារថ្នាក់ក្រុង/ស្រុក និង អង្គការការីតាស | 44 លើក | 14,106 នាក់ | 6,227 នាក់ |
| | | បានផ្សព្វផ្សាយច្បាប់ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ទាំង១២ក្រុង ស្រុក ដល់ប្រជាពលរដ្ឋ។ | | 245 លើក | 17,812 នាក់ | 10,062 នាក់ |
| | | បានផ្សព្វផ្សាយច្បាប់ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅក្នុងស្រុកក្រឡាញ់ និងស្រុស្វាយលើ។ | | 37 លើក | 4,812 នាក់ | 2,560 នាក់ |
| | | អង្គការការីតាស បានផ្សព្វផ្សាយ ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅឃុំគោកធ្លកក្រោម ស្រុកជីក្រែង ។ | | 1 លើក | 157 នាក់ | 128 នាក់ |
| 10 | ពោធិ៍សាត់ | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកក្រគរ និងស្រុក ភ្នំក្រវាញ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 15 លើក | 1,811 នាក់ | 799 នាក់ |
| | | ផ្សព្វផ្សាយ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកបាកាន ,ស្រុកក្រគរ និងស្រុក ភ្នំក្រវាញ ។ | ក្រុមការងារថ្នាក់ស្រុក | 201 លើក | 28,794 នាក់ | 15,152 នាក់ |
| 11 | កំពង់ឆ្នាំង | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ៩យ៉ាង អំពីគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក | 413 លើក | 50,874 នាក់ | 26,834 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 433 លើក | 52,106 នាក់ | 27,950 នាក់ |
| | | បានផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ នៅក្នុងភូមិព្រៃក្រាល ,ភូមិ/ឃុំព្រៃមូល ,ភូមិតាំងបំ ពង់ ,ភូមិជើងត្រាវ ស្រុករលាប្អៀរ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 200 នាក់ | 166 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 12 | រតនៈគិរី | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដោយបញ្ច្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 23 លើក | 4,319 នាក់ | 1,391 នាក់ |
| 13 | ឧត្តរមានជ័យ | វេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ យន្តការទេសន្តរប្រវេសន៍ និងការកេងប្រវ័ញ្ចនានា ដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋ ទូទាំងក្រុង/ស្រុក។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក | 5 លើក | 1,534 នាក់ | 737 នាក់ |
| 14 | ព្រះសីហនុ | ផ្សព្វផ្សាយតាមរយៈគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋានខេត្ត ថ្នាក់ក្រុង ស្រុក និងស្នងការដ្ឋាននគរបាលខេត្ត | 8 លើក | 668 នាក់ | 421 នាក់ |
| | | ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ ។ | | 5 លើក | 721 នាក់ | 352 នាក់ |
| 15 | តាកែវ | ផ្សព្វផ្សាយច្បាប់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | លេខាធិការដ្ឋានខេត្ត ថ្នាក់ក្រុង ស្រុក | 19 លើក | 1,302 នាក់ | 1,262 នាក់ |
| 16 | តាកែវ | ផ្សព្វផ្សាយច្បាប់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | លេខាធិការដ្ឋានខេត្ត ថ្នាក់ក្រុង ស្រុក | 299 លើក | 13,702 នាក់ | 7,517 នាក់ |

សកម្មភាពសរុបៈចំនួន: 3,192 លើក

មនុស្សសរុបចំនួន: 519,813 នាក់

ស្រីសរុបចំនួន : 168,062 នាក់

## ឧបសម្ព័ន្ធទី២

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន៣៨លើក )

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ បាន ៖ | - ដឹកនាំកិច្ចប្រជុំដកពិសោធន៍លើការងារសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- អញ្ជើញជាអធិបតីក្នុងអង្គមិទ្ទិញអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ នៅខេត្តបន្ទាយមានជ័យ ។<br>- អញ្ជើញចូលរួមក្នុងអង្គមិទ្ទិញអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ "ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេច ក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ (គ.ជ.ប.ជ ) នៅទីស្តីការក្រសួងមហាផ្ទៃ ។<br>- ដឹកនាំប្រជុំពិភាក្សាកំណត់សមាសភាពគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូងសាន ខេត្តអានហួយ សាធារណៈរដ្ឋប្រជាមានិតចិន ពីថ្ងៃទី២១-២៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ដឹកនាំប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីលទ្ធផលការងាររបស់ក្រុមការងារទេសន្តរប្រវេសន៍នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ និងធ្វើផែនការចុះសហការធ្វើការងារនេះបន្តទៀតជាមួយអង្គភាពពាក់ព័ន្ធនៅតាមព្រំដែន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ដឹកនាំប្រជុំពិភាក្សា ការវាយតម្លៃអំពីលំហូរពលករខ្មែរមកពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា នៅទីក្រុងហូងសាន ខេត្តអានហួយ សាធារណៈរដ្ឋប្រជាមានិតចិន ។<br>- អញ្ជើញជាអធិបតីបើកសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធ ប្រឆាំងអំពើជួញដូរពលកម្ម ដែលរៀបចំ និងសម្របសម្រួលដោយអង្គការ IJM នៅសាលប្រជុំសាខា កាកបាទក្រហមខេត្តព្រៃវែង មានសិក្ខាកាមចូលរួមប្រមាណ **៧០**នាក់ ។<br>- អញ្ជើញចូលរួមប្រជុំក្នុងពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ជាតិ ស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ ។ |

| | |
|---|---|
| | - អញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសគណៈកម្មការការពារកុមារថ្នាក់ជាតិ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគំនិតផ្តួចផ្តើមនៃប្រព័ន្ធកិច្ចការពារកុមារ និងការកំណត់នូវចក្ខុវិស័យ ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ នៅភោជនីយ៍ដ្ឋានអ័រគីដេប៉ាស្ទ័រ ។ |
| **អគ្គស្នងការ** | - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូនមន្ត្រីនគរបាលចំនួន០៥រូប ចូលរួមវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ (នៅបណ្ឌិត្យសភានគរបាលកម្ពុជា ។ |
| ខេត្តបាត់ដំបង | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ដល់មន្ត្រីពាក់ព័ន្ធក្រុង/ស្រុក ឃុំ/សង្កាត់ ស្តីពី យុត្តិធម៌ អនីតិជន និងស្ត្រី រៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារស្ទឹងបាត់ដំបង ។<br>- បានចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងឱកាសការងារនៅក្នុងប្រទេស នៅឃុំបឹងរាំង ស្រុកកំរៀង។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចាត់តាំងមន្ត្រីជំនាញចំនួន០១នាក់ បានចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការ AAPTIP មានសិក្ខាកាមសរុបចំនួន២៤នាក់(ស្រី)។ |
| **ខេត្តឧត្តរមានជ័យ** | - ចូលរួមសិក្ខាសាលា ស្តីពីគោលគំនិតយេនឌ័រ ក្នុងការបង្ការទប់ស្កាត់ការជួញដូរមនុស្ស នៅសាលាខេត្ត សរុបអ្នកចូលរួមចំនួន៤៤នាក់ (ស្រី៣៨នាក់)។ |
| | - |
| ខេត្តសៀមរាប | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលរៀបចំកិច្ចប្រជុំប្រចាំខែមេសា ឆ្នាំ២០១៧ របស់ក្រុមការងារទេសន្តរប្រវេសន៍ ដែលមានអ្នកចូលរួមសរុបចំនួន៤០នាក់ (ស្រី២១នាក់)។<br>- មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត ០៩ប្រធានបទ ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំពិភាក្សាជាមួយអង្គការមូណូហាស៊ី ស្តីពីការរំលោភបំពានលើកុមារ និង ការប្រព្រឹត្តផ្លូវភេទលើកុមារ ដែលជនបរទេសបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា និងការសហការរៀងអង្គការជាមួយការិយាល័យជំនាញ មានចំនួន០៨នាក់ និងបុគ្គលិកអង្គការចំនួន០៤នាក់ ។ |
| **ខេត្តកំពង់ធំ** | - ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមសិក្ខាសាលា បើកវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ នៅសាលប្រជុំផ្ទះសំណាក់ពន្លឺថ្មី ។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពី ការស៊ើបអង្កេតបទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា រយៈពេល០៣ថ្ងៃ នៅរាជធានីភ្នំពេញ ។ |

| | |
|---|---|
| | - ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានធ្វើសំណើសុំធ្វើកិច្ចអន្តរាគមន៍ ពលករដែលកំពុងធ្វើការតាមផ្ទះកំពុងមានបញ្ហានៅប្រទេសម៉ាឡេស៊ី ចង់ត្រឡប់មកស្រុកកំណើតវិញ ។ |
| **ខេត្តស្ទឹងត្រែង** | - ស្នងការដ្ឋាននគរបាលខេត្ត ចាត់តាំងមន្ត្រីជំនាញចំនួន០១នាក់ បានចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា នៅរាជធានីភ្នំពេញ។ |
| ខេត្តកំពង់ចាម | - នាយរងការិយាល័យទទួលបន្ទុកប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ និងទូរទស្សន៍ជាតិខេត្ត ក្រោមប្រធានបទផ្សព្វផ្សាយ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ដែលជ្រកក្រោមផ្លាកខារ៉ាអូខេ និងហាងម៉ាស្សា នៅមន្ទីរព័ត៌មានខេត្ត ។ |
| ខេត្តបន្ទាយមានជ័យ | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០៣រូប ប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសន៍ពលករដែលអាជ្ញាធរថៃបញ្ជូនមក និង ស្រាវជ្រាវរកមុខសញ្ញាពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមវេទិកា សំនួរ ចម្លើយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការយល់ដឹងអំពីអំពើជួញដូរមនុស្ស បានចំនួន០៤ឃុំ (ឃុំតាប៉ែន ឃុំទ្រាស ,ឃុំតាផូ ,ឃុំផ្គាំ ) ។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ និងផ្សព្វផ្សាយទិសដៅបន្តការងារក្នុងឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ។ |
| **ខេត្តប៉ៃលិន** | - គណៈកម្មាធិការ គ.ខ.ប.ជ បានសហការជាមួយក្រុមការងារលេខាធិការដ្ឋានថ្នាក់ក្រុង ចូលរួមប្រជុំសាមញ្ញលើកទី៣៣របស់ គ ក ស ក ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ នៅសាលាក្រុងចំនួន០១លើក មានអ្នកចូលរួមចំនួន២១នាក់ (ស្រី១១នាក់) ។ |
| **ខេត្តព្រះសីហនុ** | - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពីការសម្ភាសន៍កុមារមេត្រី និងការស៊ើបអង្កេតអំពើរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលរៀបចំដោយអង្គការ APLE នៅសណ្ឋាគារឆ្នេរថ្មី ។ |
| **ខេត្តកំពត** | - គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តការងារដឹកនាំ និងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅក្នុងខេត្តទាំងមូល ។ |
| ព្រៃវែង | - គណៈកម្មាធិការពិគ្រោះយោបល់ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការប្រជុំប្រចាំខែ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនតាមរយៈ ពិធីមង្គលការ ពិធីបុណ្យ និងពិធីកំសាន្តផ្សេងៗ ។ |
| **ស្វាយរៀង** | - ក្រុមការងារលេខាធិការដ្ឋានថ្នាក់ខេត្ត បានសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបើកកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ដល់សមាជិ សមាជិការក្រុមប្រឹក្សាជាតិកម្ពុជាខេត្ត មន្ត្រីនៃមន្ទីរសង្គមកិច្ចខេត្ត ក្រុង/ស្រុក ចំនួន០១លើក មានអ្នកចូលរួមចំនួន៥០នាក់ ស្រី១៩នាក់ ។ |

| | |
|---|---|
| ខេត្តកណ្តាល | - ក្រុមការងារលេខាធិការដ្ឋានថ្នាក់ស្រុក បានបើកកិច្ចប្រជុំប្រចាំខែ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួម១២៦នាក់ ស្រី៩០នាក់ ( ០៥លើក ) ។ |